ក្រសួងអប់រំរដ្ឋ NSW

## Notice of expulsion - unsatisfactory participation in learning for students aged 17 years and over

### Using the telephone interpreter service to contact the school

# សេចក្តីជូនដំណឹងអំពីការបណ្តេញចេញ - ការចូលរួមក្នុងការរៀនសូត្រមិនសមតាមបំណង សម្រាប់សិស្សដែលមានអាយុចាប់ពី 17 ឆ្នាំឡើងទៅ

### ការប្រើសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីទាក់ទងសាលារៀន

ឈ្មោះសិស្ស
Name of student

សូមគោរពឪពុកម្តាយ/អ្នកថែទាំ

លិខិតដែលភ្ជាប់មកជាមួយនេះ រៀបរាប់លម្អិតនៃសេចក្តីជូនដំណឹងអំពីការបណ្តេញចេញ - ការចូលរួមមិនសមតាមបំណង ដែលខ្ញុំបានចេញឱ្យកូនរបស់អ្នក ដោយអនុលោមតាមគោលនយោបាយអាកប្បកិរិយាសិស្សរបស់ក្រសួងអប់រំរដ្ឋ NSW និងនីតិវិធីការបញ្ឈប់បណ្តោះអាសន្ន និងការបណ្តេញចេញ។

កូនរបស់អ្នកនឹងមិនអាចត្រឡប់ទៅសាលារៀននេះវិញបានទេ ដោយគ្មានការអនុញ្ញាតពីនាយកសាលា។ នេះជាទំនួលខុសត្រូវរបស់អ្នកក្នុងការស្វែងរកកន្លែងរៀនសូត្រជំនួសសមស្របសម្រាប់កូនរបស់អ្នក ប្រសិនបើអ្នកចង់ឱ្យពួកគេបន្តការអប់រំ។ អ្នកអាចទាក់ទងមកសាលារៀន ប្រសិនបើអ្នកត្រូវការដំបូន្មានបន្ថែមអំពីជម្រើសនានាដែលអាចធ្វើបាន។

ភ្ជាប់មកជាមួយនេះ គឺជាព័ត៌មាននិយាយអំពីអ្វីៗដែលអ្នកចាំបាច់ត្រូវដឹង ប្រសិនបើកូនរបស់អ្នកត្រូវបានបណ្តេញចេញ។

ប្រសិនបើអ្នកមានការពិបាកយល់អំពីលិខិតដែលភ្ជាប់មកជាមួយ សូមទាក់ទងសាលារៀនដើម្បីឱ្យពួកយើងអាចពន្យល់ជូនអ្នក។ ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ នៅពេលទាក់ទងសាលារៀន សូមហៅទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

ឈ្មោះនាយកសាលា
Name of Principal

លេខទូរសព្ទរបស់នាយកសាលា
Principal’s phone number